ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ : ០៣៦៧/១០ ក.អ.ជ

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ ធ្នូ ឆ្នាំ២០១០

**រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**ជម្រាបមក**

**លោក រចំ ជ្វីន តំណាងសហគមន៍ជនជាតិដើមភាគតិច ចារ៉ាយ**

**ភូមិគងធំ ឃុំប៉ាតេ ស្រុកអូរយ៉ាដាវ**

**កម្មវត្ថុ** ÷ ស្តីពីការទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច **ចារ៉ាយ** ភូមិគងធំ ឃុំប៉ាតេ ស្រុកអូរយ៉ាដាវ

**យោង** ÷ - លិខិតចុះថ្ងៃទី០៥ ខែ មេសា ឆ្នាំ ២០១០ ស្តីពីការស្នើសុំទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច **ចារ៉ាយ** ភូមិគងធំ របស់លោក រចំ ជ្វីន តំណាងសហគមន៍។

- លិខិតលេខ២៤៣/១០ ល.អ.ខ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០១០ ស្តីពីការទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច **ចារ៉ាយ** ភូមិគងធំ របស់អភិបាល នៃគណៈអភិបាលខេត្តរតនគិរី។
- លទ្ធផលវាយតម្លៃអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច **ចារ៉ាយ** ភូមិគងធំ របស់ក្រុមការងារនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច នៃក្រសួងអភិវឌ្ឍន៍ជនបទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមលោកជ្រាបថា ក្រសួងអភិវឌ្ឍន៍ជនបទយល់ព្រមទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច **ចារ៉ាយ** ភូមិគងធំ ឃុំប៉ាតេ ស្រុកអូរយ៉ាដាវ ខេត្តរតនគិរី តាមសំណើ។ សហគមន៍ជនជាតិដើមភាគតិច **ចារ៉ាយ** ភូមិគងធំ អាចប្រើប្រាស់លិខិតទទួលស្គាល់អត្តសញ្ញាណនេះក្នុងសកម្មភាពបម្រើដល់ផលប្រយោជន៍រួមរបស់សហគមន៍ ផលប្រយោជន៍សង្គម និងផលប្រយោជន៍ជាតិ តាមការចាំបាច់ស្របតាមគោលនយោបាយ ច្បាប់ បទបញ្ញា និងលិខិតបទដ្ឋានទាំងឡាយ នៃព្រះរាជាណាចក្រកម្ពុជា។

សូមលោក ទទួលនូវសេចក្តីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

ជា សុផារ៉ា

*ចម្លងជូន*

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-ក្រសួងទេសចរណ៍
-ក្រសួងបរិស្ថាន
"ដើម្បីជូនជ្រាប"
-សាលាខេត្តរតនគិរី
-មន្ទីរអភិវឌ្ឍន៍ជនបទខេត្តរតនគិរី
"ដើម្បីមុខការ"
-ឯកសារ កាលប្បវត្តិ